# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and the WSD Handa Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ១៩

ចាប់ពីថ្ងៃទី១៨ រហូតដល់ទី២១ ខែឧសភា ឆ្នាំ២០១៥ អង្គជំនុំជម្រះសាលាដំបូង បានបិទបញ្ចប់ការផ្តល់សក្ខីកម្មរបស់សាក្សីចុងក្រោយ ដែលបានផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងមន្ទីរសន្តិសុខក្រាំងតាចាន់ ហើយអង្គជំនុំជម្រះក៏បានចាប់ផ្តើមកិច្ចដំណើរការនីតិវិធីជំនុំជម្រះផ្នែកបន្ទាប់ក្នុងសំណុំរឿង ០០២ វគ្គទី២ នេះផងដែរ។ ផ្នែកជំនុំជម្រះបន្ទាប់ គឺការដ្ឋានទំនប់១មករាដែលសព្វថ្ងៃស្ថិតក្នុងខេត្តកំពង់ធំ មានភាពពាក់ព័ន្ធទៅនឹងបទចោទនានានៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មានដូចជា៖ ការធ្វើឲ្យទៅជាទាសករ ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា ក៏ដូចជាអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជា "ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស" ការបាត់ខ្លួនដោយបង្ខំ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។[១] នៅថ្ងៃចន្ទនេះ សាក្សីលោកស្រី **វ៉ង សារុន** បានផ្តល់សក្ខីកម្មស្តីពីការចាប់ខ្លួន និងការឃុំខ្លួនគាត់នៅមន្ទីរសន្តិសុខក្រាំងតាចាន់។ នៅថ្ងៃអង្គារ ដល់ថ្ងៃព្រហស្បតិ៍ លោក **ឱ ហូ** និងលោក **ពេជ្រ សុខា** បានផ្តល់សក្ខីកម្មស្តីពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគាត់ជុំវិញការរស់នៅ និងធ្វើការនៅការដ្ឋានទំនប់១មករា។ បន្ទាប់ពីមានការពិភាក្សាដេញដោលគ្នាយ៉ាងក្តៅគគុក ស្តីពីការប្រើប្រាស់ភស្តុតាងដែលបានមកពីទារុណកម្មអស់រយៈពេលបីបួនសប្តាហ៍ចុងក្រោយនេះ អង្គជំនុំជម្រះសាលាដំបូង បានប្រកាសថានឹងបើកសវនាការស្តាប់ទឡ្ហីករណ៍

[១] វាក្យខណ្ឌ ៣៥១ ដល់ ៣៦៧ ក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២ ដែលបង្ហាញពីបទចោទប្រកាន់នានា ទាក់ទងនឹងការដ្ឋានទំនប់១មករា។

ដោយផ្ទាល់ពីសំណាក់ភាគីទាំងអស់នៅថ្ងៃចន្ទ ទី២៥ ខែឧសភា នៅសប្តាហ៍បន្ទាប់នេះ ហើយនិងចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរលើបញ្ហានេះតាមពេលក្រោយ។[២]

[*] របាយការណ៍នេះ ត្រូវបានសរសេរដោយ ស្តេហ្វានី ហ្វង់ (Stephanie Fung) លៀ ហ៊ូបើ (Lea Huber), ម៉ាលេនី ហៃដ៍ (Melanie Hyde), លី ហួតផេង, ដាញ៉ែល ម៉ាតថេស៍ (Daniel Mattes), តាយ លីណា, ថោង វិច្ចិកា, ភីនីឡូភី វ៉ាន់ ធូល (Penelope Van Tuyl) និង វង្ស ឧត្តម ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និង ការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោងផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដាសម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌ អន្តរជាតិ (WSD Handa Center) ដែលកាលពីមុន ត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានា ក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

[២] របាយការណ៍លេខ ១៨ របស់អ្នកឃ្លាំមើលសវនាការសាលាក្តីលើសំណុំរឿង០០២ វគ្គទី២ សវនាការលើកស្តុតាង សប្តាហ៍ទី១៥ (ថ្ងៃទី៤ ដល់ ទី៨ ខែឧសភា ឆ្នាំ២០១៥ ទំព័រ ៧។